សកម្មភាពរួម ដំណោះស្រាយរួម

MEKONG RIVER COMMISSION
MRC
FOR SUSTAINABLE DEVELOPMENT

# កិច្ចសន្ទនាឆ្លងដែន

ក្រោម

## គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ




អាងទន្លេមេគង្គ
គម្រោងឆ្លងដែន
1 គម្រោងគ្រប់គ្រងតំបន់ដីសើមនៅអាងទន្លេសេបាងហ៊ាង និងអាងទន្លេណាមកាំ
2 គម្រោងគ្រប់គ្រងជលផលនៅទន្លេមេគង្គនិងទន្លេសេកុង
3 គម្រោងគ្រប់គ្រងធនធានទឹកនៅអាងទន្លេសេសាន និងអាងស្រែពក
4 គម្រោងគ្រប់គ្រងធនធានទឹកនៅដែនដីសណ្ដទន្លេមេគង្គ
5 គម្រោងពង្រឹងកិច្ចសហប្រតិបត្តិរវាងអាងទន្លេសាប និងអាងទន្លេសុងក្លា
ចិន
មីយ៉ាន់ម៉ា
ឡាវ
វៀងច័ន្ទ
ថៃ
វៀតណាម
បាងកក
កម្ពុជា
ភ្នំពេញ
Nam Kam
Xe Bang Hieng
Mekong
Sekong
Sesan
Srepok
Tonle Sap Lake
Gulf of Thailand
Songkhla Lake
N

# កិច្ចសន្ទនាឆ្លងដែនក្នុងតំបន់មេគង្គ

ទន្លេមេគង្គហូរចម្ងាយ ៤.៩០០ គីឡូម៉ែត្រ ដោយឆ្លងកាត់ប្រទេសចំនួនប្រាំមួយនៅអាស៊ី ចាប់ពីប្រទេសចិន រហូតដល់ប្រទេសវៀតណាមមុនពេលហូរចូលសមុទ្រ។ វាជាទន្លេមួយក្នុងចំណោមទន្លេធំជាងគេ និង សម្បូរធនធានជីវចម្រុះបំផុតលើពិភពលោក ដែលផ្តល់នូវប្រព័ន្ធអេកូឡូស៊ី និងធនធានធម្មជាតិដ៏សម្បូរបែប ដល់ប្រទេសតាមដងទន្លេ និងប្រជាជននៃប្រទេសទាំងនេះ។ ការគ្រប់គ្រងធនធានហួសពីព្រំដែនជាតិ មានសារៈសំខាន់ណាស់ ដោយសារទឹកត្រី និងកំទេចកំណក ហូរឆ្លងកាត់ពីប្រទេសមួយទៅប្រទេសមួយផ្សេងទៀត។ ការគ្រប់គ្រងទន្លេដែលលាតសន្ធឹងកាត់ព្រំដែនប្រទេសបែបនេះ គឺជាការលំបាកមួយសម្រាប់បណ្តាប្រទេសក្នុងតំបន់មេគង្គ ដោយហេតុថាប្រទេសនីមួយៗ មានផលប្រយោជន៍ និងអាទិភាពជាតិខុសៗគ្នា។

កិច្ចសន្ទនាឆ្លងដែន អាចជួយកាត់បន្ថយភាពតានតឹង និង បង្កើនកិច្ចសហប្រតិបត្តិការក្នុងចំណោមប្រទេសពាក់ព័ន្ធ។ គណៈកម្មការទន្លេមេគង្គ (MRC) ជួយប្រទេសជាសមាជិកទាំង ៤ ក្នុងអាងទន្លេមេគង្គក្រោម ពោលគឺ កម្ពុជា ឡាវ ថៃ និងវៀតណាម ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការឆ្លងដែន តាមរយៈគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ (M-IWRMP)។ គម្រោងនេះជម្រុញការអនុវត្តគោលការណ៍ IWRM ដើម្បីសម្របសម្រួលការរៀបចំផែនការ និងការគ្រប់គ្រងធនធានទឹក ដោយប្រើប្រាស់នីតិវិធីរបស់ MRC និងឧបករណ៍បច្ចេកទេសស្តីពីការរៀបចំផែនការប្រើប្រាស់ទឹក ការចែករំលែកទិន្នន័យ និងការតាមដានលំហូរទឹក។

គម្រោងនេះបានចាប់ផ្តើមលេចរូបរាងនៅឆ្នាំ ២០០៩ ដែលរួមបញ្ចូលសមាសភាគចំនួន៣ គឺសមាសភាគគម្រោងថ្នាក់តំបន់ឆ្លងដែននិងថ្នាក់ជាតិ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការលើផ្នែកធនធានទឹកក្នុងចំណោមប្រទេសទាំង ៤ ទាំងនៅកម្រិតអាងទន្លេនិងថ្នាក់មូលដ្ឋាន ដោយផ្អែកលើគោលការណ៍ IWRM។ សមាសភាគគម្រោងថ្នាក់តំបន់ ដែលទទួលមូលនិធិគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី បានបញ្ចប់នៅឆ្នាំ ២០១៥ ក្រោយពីបានធ្វើឲ្យប្រសើរឡើងនូវនីតិវិធី របស់ MRC និង គោលការណ៍ណែនាំបច្ចេកទេសនានា និង បានរៀបចំឧបករណ៍ម៉ូដែល



សម្រាប់ការបែងចែកការប្រើប្រាស់ទឹកជាទ្រង់ទ្រាយធំ រួចមក។

ស្របពេលដែលសមាសភាគគម្រោងឆ្លងដែន ផ្តោតលើកិច្ចសហប្រតិបត្តិការទ្វេភាគី ទាក់ទងនឹងធនធានទឹក សមាសភាគគម្រោងនៅថ្នាក់ជាតិ ជួយប្រទេសជាសមាជិកនីមួយៗ កែលំអយន្តការអភិបាលកិច្ច និង កសាងសមត្ថភាពបច្ចេកទេស ដើម្បីរៀបចំផែនការ និង អនុវត្តន៍កិច្ចការប្រើប្រាស់ទឹកប្រកបដោយការសម្របសម្រួល នៅក្នុងព្រំដែនរបស់ប្រទេស។ ធនាគារពិភពលោក ផ្តល់ហិរញ្ញវត្ថុសម្រាប់គាំទ្រ ទាំងសមាសភាគគម្រោងនៅកម្រិតថ្នាក់ជាតិ និង ឆ្លងដែន។

# ពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី

នៅក្រោមសមាសភាគគម្រោងឆ្លងដែន ប្រទេសទាំង ៤ បានបង្កើតគម្រោងទ្វេភាគីចំនួន ៥ ដែលផ្តោតលើការគ្រប់គ្រងជលផល តំបន់ដីសើម ដែនដីសណ្ត បឹង និងអាងទន្លេ ដើម្បីដោះស្រាយបញ្ហាទឹកឆ្លងដែន ដែលបង្កដោយសម្ពាធពីការអភិវឌ្ឍន៍ទីក្រុង ហេដ្ឋារចនាសម្ព័ន្ធ និងការប្រែប្រួលអាកាសធាតុ ដែលប៉ះពាល់ដល់សហគមន៍តាមដងទន្លេជាប់ព្រំដែនរវាងប្រទេសទាំងនេះ។

តាមរយៈកិច្ចសន្ទនាឆ្លងដែន ប្រទេសទាំង ៤ បានបង្កើតឲ្យមានការយល់ដឹងរួមគ្នា អំពីបញ្ហាឆ្លងដែនដែលទាក់ទងនឹងធនធានទឹក ស្វែងរកដំណោះស្រាយយូរអង្វែងដើម្បីធ្វើការជាមួយគ្នា និង ចែករំលែកទម្លាប់អនុវត្តល្អៗក្នុងការគ្រប់គ្រងធនធានទឹក។ ជារួម គម្រោងទាំងនេះត្រូវបានបង្កើតឡើង ដើម្បីពង្រឹងសមត្ថភាពនៅថ្នាក់ជាតិ និង ថ្នាក់ខេត្ត ដើម្បីសម្របសម្រួលការប្រើប្រាស់ទឹក និង ជួយឲ្យក្របខ័ណ្ឌស្ថាប័ន មានលក្ខណៈប្រសើរជាងមុន សម្រាប់រួមគ្នាគ្រប់គ្រងធនធានទឹកឆ្លងដែន ដោយផ្អែកលើគោលការណ៍ IWRM។

គម្រោងទ្វេភាគីទាំងនេះ បានចាប់ផ្តើមអនុវត្តន៍នៅចន្លោះឆ្នាំ ២០១៣ និង ២០១៤ និង គ្រោងបញ្ចប់នៅខែមីនា ឆ្នាំ២០១៨។ មានការរំពឹងទុកថា កិច្ចសហការទ្វេភាគីដែលផ្អែកលើគោលការណ៍ IWRM នឹងត្រូវបន្តអនុវត្តន៍បន្ទាប់ពីគម្រោងនេះបានបញ្ចប់ ដោយហេតុថាមេរៀននានាដែលទទួលបានពីគម្រោងនេះ បានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ថ្មីៗនៅថ្នាក់ជាតិ។ កិច្ចសហការនេះ នឹងផ្តល់អត្ថប្រយោជន៍ដល់មុខរបរចិញ្ចឹមជីវិតរបស់សហគមន៍នៅតាមដងទន្លេ និងពង្រឹងការអភិវឌ្ឍនៅក្នុងតំបន់នេះឲ្យកាន់តែមានចីរភាព។

## គម្រោងទាំង ៥ នេះ រួមមាន៖

- → **គម្រោងគ្រប់គ្រងជលផលនៅទន្លេមេគង្គ និង ទន្លេសេកុង** រវាងប្រទេសកម្ពុជា និងឡាវ ដែលដោះស្រាយបញ្ហាធ្លាក់ចុះនៃប្រភេទត្រី ស ដែលធ្វើបំលាស់ទីឆ្ងាយដើម្បីធ្វើឲ្យការគ្រប់គ្រងធនធានត្រីប្រសើរឡើង។
- → **គម្រោងគ្រប់គ្រងធនធានទឹកនៅអាងទន្លេសេសាន និង អាងទន្លេស្រែពក** ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការឆ្លងដែនរវាងកម្ពុជានិងវៀតណាម ស្របពេលមានការអភិវឌ្ឍន៍ថាមពលវារីអគ្គិសនី។
- → **គម្រោងគ្រប់គ្រងធនធានទឹកនៅដែនដីសណ្តទន្លេមេគង្គ** នៅក្នុងបណ្តាខេត្តជាប់ព្រំដែននៃប្រទេសកម្ពុជា និងវៀតណាម ដើម្បីដោះស្រាយការប្រឈមនានាបង្កឡើងដោយការអភិវឌ្ឍន៍នៅតំបន់ខ្សែទឹកខាងលើ និងការប្រែប្រួលអាកាសធាតុ។
- → **គម្រោងគ្រប់គ្រងតំបន់ដីសើមនៅអាងទន្លេសេបាងហ៊ាង និងអាងទន្លេណាមកាំ** រវាងប្រទេសឡាវ និងថៃ ដើម្បីពង្រឹងការគ្រប់គ្រងធនធានតំបន់ដីសើម តាមរយៈការចែករំលែកចំណេះដឹង។
- → **គម្រោងពង្រឹងកិច្ចសហប្រតិបត្តិការរវាងអាងទន្លេសាប និងអាងទន្លេសុងក្លា** រវាងប្រទេសកម្ពុជា និងថៃ ដើម្បីលើកកម្ពស់អភិបាលកិច្ចបឹងឲ្យបានរឹងមាំ តាមរយៈសកម្មភាពប្រាស្រ័យទាក់ទង។







# តើគណៈកម្មការទន្លេមេគង្គ (MRC) ជាអ្វី?

គណៈកម្មការទន្លេមេគង្គ (MRC) បានបង្កើតឡើងដោយកិច្ចព្រមព្រៀងមេគង្គ ឆ្នាំ១៩៩៥ រវាងកម្ពុជា ឡាវ ថៃ និង វៀតណាម ដើម្បីការអភិវឌ្ឍន៍ធនធានទឹកក្នុងតំបន់នេះប្រកបដោយចីរភាព តាមរយៈកិច្ចសន្ទនា និង សហប្រតិបត្តិការ។គណៈកម្មការនេះ ផ្តល់ជាវេទិកាសម្រាប់កិច្ចការទូតអំពីបញ្ហាការប្រើប្រាស់ទឹក ដល់រដ្ឋាភិបាល នៃប្រទេសទាំង ៤ ដើម្បីចរចា និងចែករំលែកផលប្រយោជន៍ពីធនធានទឹករួម និងដើរតួជាមជ្ឈមណ្ឌលចំណេះ ដឹងអំពីការគ្រប់គ្រងអាងទន្លេ ដោយភ្ជាប់ជាមួយនូវគោលការណ៍ណែនាំបច្ចេកទេស ឧបករណ៍ និងទិន្នន័យ វិទ្យាសាស្ត្រ។



# តើការគ្រប់គ្រងធនធានទឹកចម្រុះ (IWRM) ជាអ្វី?

ការគ្រប់គ្រងធនធានទឹកចម្រុះ (IWRM) គឺជាសញ្ញាណសកលមួយនៃការរៀបចំផែនការ និង ការប្រើប្រាស់ធនធានទឹកដោយមានការសម្របសម្រួល ក្នុងគោលដៅធ្វើឲ្យមានតុល្យភាព រវាងតម្រូវការសម្រាប់ការអភិវឌ្ឍន៍សង្គមនិងសេដ្ឋកិច្ច និង កិច្ចការពារបរិស្ថានក្នុងសហគមន៍តាមដងទន្លេ។ ការគ្រប់គ្រងបែបនេះ ទាមទារឲ្យមានវិធានពហុវិស័យ ដើម្បីសម្របសម្រួលតម្រូវការធនធានដែលមានភាពចម្រូងចម្រាស់ ជំនួសឲ្យវិធានដែលផ្តោតលើវិស័យតែមួយ ដែលគិតគូរតែអំពីតម្រូវការនៃវិស័យមួយៗដាច់ដោយឡែកពីគ្នា ដូចជា ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ សន្តិសុខស្បៀង និងប្រព័ន្ធអេកូឡូស៊ី ជាដើម ។ នៅក្នុងអាងទន្លេមេគង្គក្រោម វិធានពហុវិស័យត្រូវបានជម្រុញឲ្យប្រើប្រាស់នៅក្នុងប្រទេសនីមួយៗ រវាងប្រទេសនិងប្រទេស និងនៅទូទាំងអាងទន្លេ។

## តើនីតិវិធីរបស់ MRC ជាអ្វី ?

នីតិវិធីរបស់ MRC ផ្សំដោយនីតិវិធីចំនួន ៥ សម្រាប់គ្រប់គ្រងការប្រើប្រាស់ទឹក ដែលជាធនធានរួមក្នុងចំណោមប្រទេសជាសមាជិក និងជួយដល់ការអនុវត្តកិច្ចព្រមព្រៀងមេគង្គ ឆ្នាំ១៩៩៥ ស្តីពីកិច្ចសហប្រតិបត្តិការលើផ្នែកធនធានទឹក។ នីតិតិវិធីទាំងនេះ រួមមាន៖

- → នីតិវិធីសម្រាប់ការចែករំលែក និងផ្តោះប្តូរទិន្នន័យ និងព័ត៌មាន ( PDIES )
- → នីតិវិធីសម្រាប់ការតាមដានលើការប្រើប្រាស់ទឹក ( PWUM )
- → នីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង ( PNPCA )
- → នីតិវិធីសម្រាប់ការរក្សាលំហូរលើដងទន្លេមេ ( PMFM )
- → នីតិវិធីសម្រាប់គុណភាពទឹក ( PWQ )

មានការរំពឹងទុកថា នីតិវិធីទាំងនេះក៏ដូចជាទិន្នន័យស្រាវជ្រាវ គោលការណែនាំបច្ចេកទេស និងឧបករណ៍ម៉ូដែលនានារបស់ MRC នឹងអាចជួយជំរុញដល់ការអនុវត្តគោលការណ៍ IWRM នៅក្នុងតំបន់។





# គម្រោងគ្រប់គ្រងជលផលនៅទន្លេមេគង្គ និងទន្លេសេកុង

## កិច្ចសហការដើម្បីស្តារស្តុកមច្ឆជាតិ

ទន្លេសេកុង មានប្រភពនៅតំបន់ខ្ពង់រាបភាគកណ្តាលនៃប្រទេសវៀតណាម និងហូរកាត់ភាគខាងត្បូងនៃប្រទេសឡាវ និងភាគឦសាននៃប្រទេសកម្ពុជា មុននឹងជួបជាមួយទន្លេមេគង្គ។

ទន្លេទាំងពីរនេះផ្តល់ធនធានវារីវប្បកម្មដ៏សម្បូរបែប ដោយមានវារីសត្វច្រើនជាង ១២០ ប្រភេទ រួមបញ្ចូលទាំងសត្វផ្សោត ដែលមានតែនៅក្នុងតំបន់នេះ និង ពូជត្រីដែលធ្វើបំលាស់ទីច្រើនជាង ៦០ ប្រភេទ ដែលត្រូវបានរកឃើញនៅក្នុងទន្លេសេកុង និងប្រមាណ ៨០០ ប្រភេទ នៅក្នុងទន្លេមេគង្គ ដោយក្នុងនោះមានត្រីទឹកសាប ៥៨០ ប្រភេទផងដែរ។ ការនេសាទ គឺជាបង្អែកដ៏រឹងមាំនៃសេដ្ឋកិច្ចមូលដ្ឋាន និងជាប្រភពចំណូលនិងប្រូតេអ៊ីនរបស់ប្រជាជននៅក្នុងបណ្តាខេត្តជាប់ព្រំដែននៃប្រទេសកម្ពុជានិងឡាវ ដែលជាកន្លែងទន្លេទាំងពីរជួបគ្នា។

ប៉ុន្តែទន្លេទាំងពីរ ប្រឈមការគំរាមកំហែងជាច្រើន រួមទាំង ទម្លាប់នេសាទបែបបំផ្លិចបំផ្លាញ និងកំណើននៃការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដូចជា ថាមពលវារីអគ្គិសនី និងប្រព័ន្ធស្រោចស្រពកសិកម្ម ដែលនាំឲ្យមានការរេចរឹលទីជម្រកមច្ឆជាតិ។ បញ្ហានេះ ទាមទារឲ្យមានចំណាត់ការប្រកបដោយកិច្ចសហការ ពីសំណាក់សហគមន៍តាមដងទន្លេជាប់ព្រំដែននៃប្រទេសទាំងពីរ។

ប្រទេសកម្ពុជា និងឡាវ បានចាត់វិធានការមួយចំនួនហើយ ដើម្បីកាត់បន្ថយផលប៉ះពាល់នានា ប៉ុន្តែគេនៅត្រូវការវិធានការ ដែលមានលក្ខណៈសម្របសម្រួលជាងមុន ដែលអនុញ្ញាតិឲ្យប្រទេសទាំងពីរបង្កើនជាអតិប្បរិមានូវកិច្ចប្រឹង

| គម្រោងគ្រប់គ្រងជលផលនៅទន្លេមេគង្គ និង ទន្លេសេកុង | | |
|---|---|---|
| ប្រទេស៖<br>កម្ពុជា ឡាវ | ថវិកា៖<br>៥៣៥.២០០ ដុល្លារអាមេរិក | រយៈពេល៖ ខែកក្កដា ឆ្នាំ២០១៤<br>- ខែមីនា ឆ្នាំ២០១៨ |

ប្រែងដើម្បីធ្វើឲ្យប្រព័ន្ធអេកូឡូស៊ី និងធនធានជលផលតាមដងទន្លេនេះ កាន់តែមាននិរន្តរភាព។




## សកម្មភាពរួម ដើម្បីដំណោះស្រាយយូរអង្វែង

គម្រោងគ្រប់គ្រងជលផលនៅទន្លេមេគង្គ និងទន្លេសេកុង ជួយប្រទេសកម្ពុជា និងឡាវ បង្កើតយន្តការសមស្របសម្រាប់ការគ្រប់គ្រងធនធានជលផលនៅតាមបណ្ដាខេត្តជាប់ព្រំដែននៃទន្លេទាំងពីរឲ្យបានប្រសើរជាងមុន។ ខេត្តទាំងនោះរួមមាន ខេត្តក្រចេះ និងស្ទឹងត្រែង នៃប្រទេសកម្ពុជា និងខេត្តអាតាពើ និងចំប៉ាសាក់ នៃប្រទេសឡាវ។

គម្រោងនេះ បានកំណត់ឃើញបញ្ហារួម ដែលប៉ះពាល់ដល់ទន្លេទាំងពីរ ជាពិសេសការថយចុះនៃប្រភេទត្រី ស ដែលធ្វើបំលាស់ទី ក្នុងចំងាយឆ្ងាយ ដោយសារតែការនេសាទច្រើនហួសកម្រិត ការរេចរឹលនៃទីជម្រាល និង ផលប៉ះពាល់ពីគម្រោងថាមពលវារីអគ្គិសនី។ ក្រុមការងារទ្វេភាគី បានជ្រើសរើសរួមគ្នានូវត្រី ស ចំនួន៥ ប្រភេទ ដែលមាន តម្លៃសម្រាប់សន្តិសុខស្បៀង ជាគោលដៅសម្រាប់ការតាមដាន។

ប្រទេសទាំងពីរ កំពុងធ្វើការជាមួយគ្នា ដើម្បីបង្កើតប្រព័ន្ធតាមដានធនធានជលផល រួមគ្នា និង ផែនការគ្រប់គ្រងជលផលមួយ សម្រាប់ដោះស្រាយបញ្ហាឆ្លងដែន។ កិច្ចប្រឹងប្រែងនេះ នឹងជួយពង្រឹងបន្ថែមនូវកិច្ចសហប្រតិបត្តិការទ្វេភាគី និង ស្ដារធនធានជលផលឡើងវិញ ដែលជួយទ្រទ្រង់សន្តិសុខស្បៀង និង កាលានុវត្តិភាពសម្រាប់ការនេសាទ។

### គម្រោងនេះ នឹងនាំមកនូវលទ្ធផលដូចខាងក្រោម៖

→ បញ្ហាគ្រប់គ្រងជលផលឆ្លងដែនដែលប្រឈមចំពោះទន្លេមេគង្គ និងទន្លេសេកុង ត្រូវបានកំណត់។

→ យន្តការសម្របសម្រួលឆ្លងដែនសម្រាប់ដោះស្រាយបញ្ហាជលផលឆ្លងដែន ត្រូវបានបង្កើតឡើង។

→ ផែនការសកម្មភាពទ្វេភាគីមួយសម្រាប់ការអនុវត្តយន្តការសម្របសម្រួល ត្រូវបានបង្កើត។



# គម្រោងគ្រប់គ្រងធនធានទឹកនៅអាងទន្លេសេសាន និង អាងទន្លេស្រែពក

## កិច្ចសហការដើម្បីការប្រើប្រាស់ធនធានទឹករួមដោយនិរន្តរភាព

ទន្លេសេសាន និងទន្លេស្រែពក គឺជាដៃទន្លេធំពីរនៃទន្លេមេគង្គ ដែលហូរកាត់ភូមិភាគកណ្តាល នៃប្រទេសវៀតណាម និងភាគឦសាននៃប្រទេសកម្ពុជា។ ទន្លេទាំងពីរ ល្បីល្បាញដោយសារតែសម្បូរប្រភេទត្រី និង តំបន់ការពារធម្មជាតិយ៉ាងធំ ដែលទ្រទ្រង់របរចិញ្ចឹមជីវិតរបស់ប្រជាជនជិត ៤ លាននាក់ និងសត្វស្លាបជាច្រើនប្រភេទ ដែលមានសារៈសំខាន់នៅកម្រិតពិភពលោក។

នៅតំបន់ខ្សែទឹកខាងលើនៃទន្លេទាំងនេះ មានការអភិវឌ្ឍន៍ជាខ្លាំង ជាពិសេស សម្រាប់ការផលិតថាមពលវារីអគ្គិសនី និងការស្រោចស្រពកសិកម្ម ស្របពេលដែលតំបន់ខ្សែទឹកខាងក្រោម ក៏ចាប់ផ្តើមមានការអភិវឌ្ឍន៍ជាទ្រង់ទ្រាយធំផងដែរ។ គម្រោងហេដ្ឋារចនាសម្ព័ន្ធទាំងនេះ បានធ្វើឲ្យប្រព័ន្ធទន្លេទាំងពីរស្ថិតក្រោមសម្ពាធកាន់តែខ្លាំងឡើង ដែលបង្កឲ្យមានទឹកជំនន់គំហុកនិងគ្រោះរាំងស្ងួត ការហូរច្រោះដី ការខូចខាតទីជម្រាល និងការខូចគុណភាពទឹកហួសពីព្រំដែនប្រទេស។

ការអភិវឌ្ឍន៍ថាមពលវារីអគ្គិសនី និងប្រព័ន្ធស្រោចស្រពខ្នាតធំ ដែលអាចកើតមាននាពេលអនាគត នឹងអាចប៉ះពាល់ថែមទៀតដល់គុណភាពទឹក និងសុខភាពនៃប្រព័ន្ធអេកូឡូស៊ីដែនទឹក ដែលនាំឲ្យមានការថយចុះធនធានជលផល និងការបាត់បង់ជីវចម្រុះ។ ផលរំខានទាំងនេះ អាចនាំឲ្យប៉ះពាល់ដល់ជីវភាពរបស់សហគមន៍នៅតាមដងទន្លេ។

| គម្រោងគ្រប់គ្រងធនធានទឹកនៅអាងទន្លេសេសាន និង អាងទន្លេស្រែពក | | |
|---|---|---|
| ប្រទេស៖<br>កម្ពុជា វៀតណាម | ថវិកា៖<br>៣៥៤.០០០ ដុល្លារអាមេរិក | រយៈពេល៖ ខែឧសភា<br>ឆ្នាំ២០១៤ - ខែមីនា ឆ្នាំ២០១៨ |




បញ្ហានេះ តម្រូវឲ្យប្រទេសទាំងពីរ សម្របសម្រួលអាទិភាពនៃការអភិវឌ្ឍន៍របស់ខ្លួនដើម្បីកាត់បន្ថយផលអវិជ្ជមាន។

ប្រទេសកម្ពុជា និងវៀតណាម បាននឹងកំពុងធ្វើការកែលម្អស្ថានភាពនេះ តាមរយៈកិច្ចសហការឆ្លងដែន។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសទាំងពីរ ចាំបាច់ត្រូវមានសហប្រតិបត្តិការឆ្លងដែន កាន់តែជិតស្និទ្ធជាងមុន ដើម្បីឲ្យការគ្រប់គ្រងធនធានទឹករួមមានភាពប្រសើរឡើង។

## សកម្មភាពរួម ដើម្បីដំណោះស្រាយយូរអង្វែង

ផ្អែកលើយន្តការនានាដែលមានស្រាប់ គម្រោងគ្រប់គ្រងធនធានទឹកនៅអាងទន្លេសេសាន និងអាងទន្លេស្រែពក ជួយប្រទេសកម្ពុជា និងវៀតណាម បង្កើតក្របខ័ណ្ឌរួមមួយ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ ទ្វេភាគីទាំងនៅថ្នាក់ជាតិ និងនៅកម្រិតអាងទន្លេ។

ប្រទេសទាំងពីរ បានកំណត់បញ្ហាអាទិភាពដែលបង្កជាឧបសគ្គក្នុងការគ្រប់គ្រង ធនធានទឹកដែលរួមមាន កង្វះយន្តការសហប្រតិបត្តិការឆ្លងដែន ការចែករំលែកព័ត៌មាន និងទិន្នន័យអំពីលំហូរទឹក ការត្រួតពិនិត្យទឹកជំនន់និងប្រព័ន្ធប្រកាសផ្តល់ព័ត៌មានមិនបានគ្រប់គ្រាន់ និង សមត្ថភាពគ្រប់គ្រងធនធាន ដែលនៅមានកម្រិត។

ក្រុមការងារថ្នាក់ជាតិនៃប្រទេសទាំងពីរ កំពុងធ្វើការជាមួយគ្នា ដើម្បីបង្កើតយន្តការសម្របសម្រួលទ្វេភាគី និងផែនការសកម្មភាពមួយ សម្រាប់ការដោះស្រាយរួមគ្នានូវបញ្ហាទឹក និងបង្កើនការចែករំលែកទិន្នន័យអំពីការប្រើប្រាស់ និងការអភិវឌ្ឍន៍ធនធានទឹក។ សកម្មភាពទាំងនេះ នឹងកាត់បន្ថយផលប៉ះពាល់នានាឲ្យនៅកម្រិតអប្បបរមា និងលើកកម្ពស់ការគ្រប់គ្រងទឹកដែលជាធនធានរួម ឲ្យមាននិរន្តរភាព។

### គម្រោងនេះ នឹងនាំមកនូវលទ្ធផលដូចខាងក្រោម៖

→ បញ្ហាគ្រប់គ្រងធនធានទឹកឆ្លងដែន ត្រូវបានកំណត់។

→ យន្តការសម្របសម្រួលឆ្លងដែន សម្រាប់ដោះស្រាយបញ្ហារួមគ្នា ត្រូវបានបង្កើតឡើង។

→ ផែនការសកម្មភាពទ្វេភាគីសម្រាប់ការអនុវត្តយន្តការនានា ត្រូវបានបង្កើតឡើង។



# គម្រោងគ្រប់គ្រងធនធានទឹកនៅដែនដីសណ្តទន្លេមេគង្គ

## ពង្រឹងការប្រើប្រាស់ទឹកដើម្បីនិរន្តរភាពនៃកំណើនសេដ្ឋកិច្ច

ដែនដីសណ្តទន្លេមេគង្គ គឺជាដែនដីសណ្តធំជាងគេទីបីលើពិភពលោក ដែលសម្បូរជីវជាតិ និងមានវិសាលភាពប្រមាណ ៥៥.០០០ គីឡូម៉ែត្រការ៉េ ដោយលាតសន្ធឹងចាប់ពីភាគកណ្តាលនៃប្រទេសកម្ពុជា ដល់ភាគខាងត្បូងនៃប្រទេសវៀតណាម។ តំបន់នេះល្បីល្បាញដោយសារតែមានវិសាលភាពធនធានធម្មជាតិដ៏ធំទូលាយ ដែលរួមមានវាលល្បាប់ភក់ ព្រៃលិចទឹក និងវាលស្រែ។ ដែនដីសណ្តមួយភាគធំ ស្ថិតនៅក្នុងប្រទេសវៀតណាម ដែលធ្វើឲ្យប្រទេសនេះក្លាយជាអ្នកផលិតស្បៀងដ៏ធំមួយនៅអាស៊ី។

ទោះជាយ៉ាងណាក៏ដោយ ដោយសារតំបន់នេះស្ថិតនៅភាគខាងចុងបង្អស់នៃប្រព័ន្ធទន្លេមេគង្គ វាងាយរងគ្រោះជាខ្លាំងដោយសារផលប៉ះពាល់ពីគម្រោងថាមពលវារីអគ្គិសនីនៅតំបន់ខ្សែទឹកខាងលើ ការទាញយកទឹកសម្រាប់ ការស្រោចស្រពនិងការការពារទឹកជំនន់ និងការប្រែប្រួលអាកាសធាតុ។

សម្ពាធទាំងនេះបង្កឲ្យមានទឹកជំនន់ និងគ្រោះរាំងស្ងួតធ្ងន់ធ្ងរ កំណើនជាតិអាស៊ីតក្នុងដី និងការជ្រាបចូលនៃទឹកប្រៃ ការបំពុលទឹកកាន់តែខ្លាំង ការរេចរឹលតំបន់ទំនាបលិចទឹក និងការថយចុះនៃចលនាកំទេចកំណាក។ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដោយគ្មានការសម្របសម្រួល និង ការគ្រប់គ្រងធនធាននៅដែនដីសណ្តដោយគ្មានការធ្វើសុខដុម្មនីយកម្មរវាងប្រទេសទាំងពីរ អាចធ្វើឲ្យស្ថានភាពនេះកាន់តែធ្ងន់ធ្ងរ។

រដ្ឋាភិបាលកម្ពុជា និងវៀតណាម បានផ្តោតការយកចិត្តទុកដាក់លើកិច្ចសហប្រតិបត្តិការក្នុងការប្រើប្រាស់ទឹកក្នុងតំបន់

| គម្រោងគ្រប់គ្រងធនធានទឹកនៅដែនដីសណ្តទន្លេមេគង្គ | | |
|---|---|---|
| ប្រទេស៖<br>កម្ពុជា វៀតណាម | ថវិកា៖<br>៣៥៤.០០០ ដុល្លារអាមេរិក | រយៈពេល៖ ខែឧសភា<br>ឆ្នាំ២០១៤ - ខែមីនា ឆ្នាំ២០១៨ |

ដីសណ្តនេះ។ ទោះជាយ៉ាងណាក៏ដោយ នៅមានកិច្ចការដែលត្រូវធ្វើបន្ថែមទៀត ដើម្បីដោះស្រាយបញ្ហាប្រឈមដ៏ស្មុគស្មាញទាំងនេះឲ្យមានប្រសិទ្ធភាព។




## សកម្មភាពរួម ដើម្បីដំណោះស្រាយយូរអង្វែង

គម្រោងគ្រប់គ្រងធនធានទឹកក្នុងដែនដីសណ្តទន្លេមេគង្គ បំពេញបន្ថែមលើវិធានការដែលមានស្រាប់របស់រដ្ឋាភិបាល ក្នុងការកាត់បន្ថយផលប៉ះពាល់នានាមកលើដែនដីសណ្ត។ គម្រោងនេះជួយប្រទេសកម្ពុជា និងវៀតណាម រៀបចំផែនការ និងយន្តការសមស្របមួយចំនួន សម្រាប់ធ្វើសុខដុមនីយកម្មការគ្រប់គ្រងធនធានទឹក និងការអភិវឌ្ឍន៍ក្នុងតំបន់នេះនាពេលអនាគត។

គម្រោងនេះ បានជួយកំណត់បញ្ហាសំខាន់ៗ ដែលជាឧបសគ្គចំពោះការគ្រប់គ្រងទឹក ដូចជា បញ្ហាខ្វះការរៀបចំផែនការរួមគ្នា សម្រាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធឲ្យបានល្អប្រសើរ និង ខ្វះយន្តការសម្របសម្រួលសម្រាប់ការចែករំលែក និងការគ្រប់គ្រងទិន្នន័យ។

បច្ចុប្បន្ន គម្រោងនេះកំពុងសម្រួលឲ្យមានកិច្ចសន្ទនាទ្វេភាគី សម្រាប់ការអភិវឌ្ឍន៍វិធានមួយ ដែលមានលក្ខណៈសម្របសម្រួល និងជម្រុញឲ្យមានសកម្មភាពរួមគ្នា ដើម្បីដោះស្រាយបញ្ហាឆ្លងដែនទាំងនេះ។ គម្រោងនេះ ក៏ជួយគាំទ្រដល់ការបង្កើតយន្តការចែករំលែកព័ត៌មាននិងទិន្នន័យ និង យុទ្ធសាស្ត្រតាមដានអាងទន្លេផងដែរ ដើម្បីធានាការប្រើប្រាស់ធនធានទឹករួមឲ្យមាននិរន្តរភាព។

សកម្មភាពទាំងអស់នេះរួមផ្សំគ្នា អាចជួយទ្រទ្រង់និរន្តរភាពនៃប្រព័ន្ធអេកូឡូស៊ីដែនដីសណ្ត ជួយសម្រេចបាននូវការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចដោយចីរភាព និងកែលំអរបរចិញ្ចឹមជីវិតក្នុងតំបន់នេះ។

### គម្រោងនេះ នឹងនាំមកនូវលទ្ធផលដូចខាងក្រោម៖

→ បញ្ហាគ្រប់គ្រងទឹកឆ្លងដែន ត្រូវបានកំណត់។

→ យន្តការសហប្រតិបត្តិការឆ្លងដែនដើម្បីដោះស្រាយបញ្ហាឆ្លងដែន ត្រូវបានបង្កើតឡើង។

→ ផែនការសកម្មភាពទ្វេភាគីដើម្បីអនុវត្តន៍យន្តការសម្របសម្រួល ត្រូវបានបង្កើតឡើង។



# គម្រោងគ្រប់គ្រងតំបន់ដីសើមនៅអាងទន្លេសេបាងហ៊ាង និង ណាមកាំ

## ជម្រុញការផ្លោះប្តូរចំណេះដឹងសម្រាប់និរន្តភាពតំបន់ដីសើម

តំបន់ដីសើមក្នុងអាងទន្លេសេបាងហ៊ាងនៃប្រទេសឡាវ និងអាងទន្លេណាមកាំនៃប្រទេសថៃ ទ្រទ្រង់របរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ដោយផ្តល់បរិស្ថានដែលមានលក្ខណៈពិសេសដាច់ដោយឡែក សម្រាប់ការធ្វើស្រែ ការនេសាទទឹកសាប និងទេសចរណ៍។

សេចាំផូន ដែលជាផ្នែកមួយនៃអាងទន្លេសេបាងហ៊ាង គឺជាតំបន់ដីសើមដែលមានសារៈសំខាន់បំផុតមួយក្នុងប្រទេសឡាវ។ តំបន់នេះត្រូវបានទទួលស្គាល់ដោយអនុសញ្ញារ៉ាមសា ថាជាតំបន់ដែលមានសារៈសំខាន់ជាអន្តរជាតិ ដោយសារមានប្រព័ន្ធអេកូឡូស៊ីដ៏សម្បូរបែប។ តំបន់នេះ មានផ្លូវទឹកជាច្រើន វាលភក់ល្បាប់ទឹកសាប និងវាលស្រែ ដែលសំខាន់សម្រាប់ការទ្រទ្រង់ជីវភាព។

ឆ្លងទៅព្រំដែនម្ខាងទៀត តំបន់ដីសើម ណុងហាន នៃអាងទន្លេណាមកាំ ក៏ផ្តល់ជាទីជម្រកសម្រាប់សត្វ និងរុក្ខជាតិផងដែរ ដោយមានត្រីច្រើនជាង ៤០ ប្រភេទ វារីរុក្ខជាតិពិសេស និងវាលស្រែលើវិសាលភាពធំធេង ដែលរួមចំណែកទ្រទ្រង់សេដ្ឋកិច្ចក្នុងមូលដ្ឋាន និងការអភិវឌ្ឍន៍សង្គម នៅភាគឦសាននៃប្រទេសថៃ។

អាងទន្លេទាំងពីរ ប្រឈមនឹងបញ្ហាស្រដៀងគ្នា ដែលគំរាមកំហែងធនធានតំបន់ដីសើមនៃប្រទេសទាំងនេះ។ បញ្ហានោះ មានដូចជា ការប្រែប្រួលអាកាសធាតុ និង តម្រូវការការប្រើប្រាស់ទឹកប្រកបដោយការប្រកួត ប្រជែង បើទោះបីជាការអភិវឌ្ឍន៍សេដ្ឋកិច្ច និង ការអភិរក្សធនធានធម្មជាតិនៅតំបន់ទាំងពីរ មានកម្រិតខុសគ្នាក៏ដោយ។

| គម្រោងគ្រប់គ្រងតំបន់ដីសើមនៅអាងទន្លេសេបាងហ៊ាង និង អាងទន្លេណាមកាំ | | |
|---|---|---|
| ប្រទេស៖<br>ឡាវ ថៃ | ថវិកា៖<br>៣៥៤.០០០ ដុល្លារអាមេរិក | រយៈពេល៖ ខែធ្នូ ឆ្នាំ២០១៣ -<br>ខែមីនា ឆ្នាំ២០១៤ |

ប្រការនេះ ធ្វើឲ្យអាងទន្លេទាំងពីរ មានលក្ខណៈសមស្របសម្រាប់ការចែករំលែកបទពិសោធន៍ និង ចំណេះដឹងឲ្យគ្នាទៅវិញទៅមក ដើម្បីលើកកម្ពស់ការគ្រប់គ្រងតំបន់ដីសើមឲ្យបានប្រសើរជាងមុន និង ទ្រទ្រង់ការអភិវឌ្ឍន៍ ដែលផ្តល់ប្រយោជន៍ដល់ជនក្រីក្រ។




## សកម្មភាពរួម ដើម្បីដំណោះស្រាយយូរអង្វែង

គម្រោងគ្រប់គ្រងតំបន់ដីសើមក្នុងអាងទន្លេសេបាងហ៊ាង និង អាងទន្លេណាមកាំ ផ្តល់ជាវេទិកាមួយសម្រាប់ការរៀនសូត្រពីគ្នាទៅវិញទៅមករវាងប្រទេសឡាវ និងថៃ អំពីការថែរក្សា និង អភិវឌ្ឍន៍ធនធានតំបន់ដីសើមឲ្យបានល្អ។

គម្រោងនេះ ពង្រីកការអនុវត្តគោលការណ៍ IWRM ដើម្បីជួយរៀបចំផែនការអាងទន្លេ ការគ្រប់គ្រងទឹកជំនន់ និង ការប្រើប្រាស់អាងស្តុកទឹកឲ្យមាននិរន្តរភាព សម្រាប់ការស្រោចស្រព ការនេសាទ និងការផ្គត់ផ្គង់ទឹក។

ក្រុមការងារទ្វេភាគី បានកំណត់គោលដៅចំនួន ៦ សម្រាប់ការសហការ និងផ្លាស់ប្តូរបទពិសោធន៍ រួមបញ្ចូលទាំងការគ្រប់គ្រងធនធនាពាក់ព័ន្ធនានា ការចែករំលែកព័ត៌មាន និង ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ ក្រុមការងារនេះ ក៏បានផ្លាស់ប្តូរទស្សនកិច្ចដើម្បីការសិក្សារៀនសូត្រពីគ្នាទៅវិញទៅមក អំពីរបៀបគ្រប់គ្រងតំបន់ដីសើម ផងដែរ។

ក្រុមការងារអនុវត្តគម្រោង បានចាប់ផ្តើមសកម្មភាពរួមមួយចំនួន ដូចជា ការបង្កើតផែនទីប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ដើម្បីរៀបចំផែនការគ្រប់គ្រងតំបន់ដីសើមថ្នាក់សហគមន៍ ក្នុងទីតាំងគម្រោងមួយចំនួនដែលបានជ្រើសរើសរួច។

### គម្រោងនេះ នឹងនាំមកនូវលទ្ធផលដូចខាងក្រោម៖

→ ក្រុមអ្នកគ្រប់គ្រងអាងទន្លេថ្នាក់សហគមន៍ ត្រូវបានបង្កើតឡើង ហើយសមត្ថភាពរបស់ពួកគេក្នុងការរៀបចំផែនការអាងទន្លេដែលផ្អែកលើគោលការណ៍ IWRM ត្រូវបានកែលម្អ។

→ មានការរៀនសូត្រពីគ្នាទៅវិញទៅមក អំពីបញ្ហាតំបន់ដីសើម និងទម្លាប់ល្អៗក្នុងការគ្រប់គ្រងនៅតំបន់ដីសើមសេចាំផូន និងណុងហាន តាមរយៈទស្សនកិច្ចសិក្សា។

→ ចំណេះដឹងលើការគ្រប់គ្រងទឹកដោយផ្អែកលើសហគមន៍ ត្រូវបានចែករំលែករវាងតំបន់ដីសើមចំនួនពីរ តាមរយៈការបង្កើតផែនការគ្រប់គ្រង ក្នុងទីតាំងគម្រោងដែលបានជ្រើសរើសរួច។



# គម្រោងពង្រឹងកិច្ចសហប្រតិបត្តិការ រវាងអាងទន្លេសាប និង អាងទន្លេសុងក្លា

## ការចែករំលែកបទពិសោធន៍ដើម្បីនិរន្តរភាពបឹង

បឹងទន្លេសាប នៃប្រទេសកម្ពុជា គឺជាប្រភពដ៏មានសារៈសំខាន់ សម្រាប់ការចិញ្ចឹមជីវិតរបស់ប្រជាជន ជាច្រើនលាននាក់ ដែលដូចគ្នានឹងបឹងសុងក្លា នៃប្រទេសថៃផងដែរ ដែលផ្តល់ប្រយោជន៍ដល់ប្រជាជន ដែលរស់នៅជុំវិញបឹងនេះ។ ការគ្រប់គ្រងធនធានក្នុងបឹងដោយសហគមន៍ គឺជាគន្លឹះមួយសម្រាប់បឹងទាំងពីរនេះ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍ អាងទន្លេមេគង្គក្រោម និងតំបន់ដទៃទៀត។

បឹងទន្លេសាប គឺជាអាងទឹកសាបធំជាងគេនៅអាស៊ីអាគ្នេយ៍ ដែលមានទំហំកើនឡើង ៦ ដងរហូតដល់ ១៥.០០០ គីឡូម៉ែត្រការ៉េ នៅពេលដែលទឹកជំនន់មានកម្រិតខ្ពស់បំផុត។ ទោះបីទឹកបឹងនេះ ហូរចេញទៅទន្លេមេគង្គនារដូវប្រាំងក៏ដោយ ចរន្តទឹកប្តូរទិសនៅក្នុងរដូវវស្សា ធ្វើឲ្យបឹងនេះដោរជន់។ វដ្តជលសាស្ត្រគួរឲ្យកត់សម្គាល់នេះ ធ្វើឲ្យផលិតភាពត្រី រុក្ខជាតិ និងសត្វព្រៃនៅក្នុងបឹងទន្លេសាបមានកម្រិតខ្ពស់ និងក្លាយជាធនធានសម្រាប់ទ្រទ្រង់អាយុជីវិតរបស់ប្រជាពលរដ្ឋកម្ពុជា។

ចំណែកអាងទន្លេសុងក្លា គឺជាបឹងធម្មជាតិធំជាងគេក្នុងប្រទេសថៃ ដែលមានទឹកសាបលាយជាមួយទឹកប្រៃ។ បឹងនេះមានទំហំ ១.០៤០ គីឡូម៉ែត្រការ៉េ ស្ថិតនៅភាគខាងត្បូងនៃប្រទេសថៃ និង ផ្តល់នូវធនធានចម្រុះបែបសម្រាប់ទ្រទ្រង់របរចិញ្ចឹមជីវិត ដូចជា តាមរយៈមុខរបរកសិកម្ម ការនេសាទ និង ទេសចរណ៍។ បឹងនេះល្បីល្បាញដោយសារសហគមន៍នៅក្នុងតំបន់ មានការប្តេជ្ញាខ្ពស់ក្នុងការដឹកនាំការងារថែរក្សា និង គ្រប់គ្រងធនធានរួមរបស់ពួកគេ។

| គម្រោងពង្រឹងកិច្ចសហប្រតិបត្តិការរវាងអាងទន្លេសាប និង អាងទន្លេសុងក្លា | | |
|---|---|---|
| ប្រទេស៖<br>កម្ពុជា ថៃ | ថវិកា៖<br>៤៥៧.០០០ ដុល្លារអាមេរិក | រយៈពេល៖ ខែតុលា ឆ្នាំ២០១៣<br>- ខែមីនា ឆ្នាំ២០១៨ |

ទិដ្ឋភាពដោយឡែកទាំងនេះ ធ្វើឲ្យបឹងទាំងពីរ មានលក្ខណៈសមស្របបំផុត ក្នុងការចែករំលែកបទពិសោធន៍រវាងគ្នា ដើម្បីឲ្យបឹងទាំងនេះស្ថិតក្នុងស្ថានភាពល្អប្រសើរ ស្របពេលដែលមានបញ្ហាប្រឈមដូចគ្នា រួមមាន ការនេសាទដែលគ្មាននិរន្តរភាព និង ផលប៉ះពាល់ពីការឡើងកម្តៅពិភពលោក។




## សកម្មភាពរួម ដើម្បីដំណោះស្រាយយូរអង្វែង

គម្រោងពង្រឹងកិច្ចសហប្រតិបត្តិការរវាងអាងទន្លេសាប និង អាងទន្លេសុងក្លា ផ្តល់កាលានុវត្តិភាពមួយសម្រាប់ប្រទេសកម្ពុជា និង ថៃ ដើម្បីពិភាក្សា និងចែករំលែកទម្លាប់អនុវត្តល្អៗក្នុងការគ្រប់គ្រងធនធានធម្មជាតិរបស់ពួកគេ។

គម្រោងនេះ បង្កើនការយល់ដឹងអំពីការគ្រប់គ្រងបឹងដោយផ្អែកលើគោលការណ៍ IWRM ដើម្បីថែរក្សាសុខភាពបឹង តាមរយៈសកម្មភាពប្រាស្រ័យទាក់ទងនៅក្នុងសហគមន៍មូលដ្ឋាន និង រវាងបឹងទាំងពីរ។ គម្រោងនេះ នឹងពង្រឹងការគ្រប់គ្រងបឹងដោយមានការចូលរួមពីសហគមន៍ ដើម្បីដោះស្រាយបញ្ហាចម្បងៗ ដែលបឹងទាំងពីរ កំពុងប្រឈម។

ការផ្លាស់ប្តូរទស្សនកិច្ច បានធ្វើឡើងដើម្បីរៀនសូត្រ និងការចែករំលែកទម្លាប់ល្អៗ ក្នុងការគ្រប់គ្រងបឹង ដូចជាការគ្រប់គ្រងជលផលដោយសហគមន៍ ការពង្រឹងការចូលរួមរបស់ស្ត្រីនិងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ កិច្ចផ្តួចផ្តើមចែករំលែកចំណេះដឹងតាមរយៈវីដេអូខ្លីៗ ក៏បានសម្រួលឲ្យមានការរៀនសូត្ររវាងគ្នាទៅវិញទៅមក តាមរយៈការផលិតវីដេអូរួមគ្នា និងការចាក់បញ្ចាំងវីដេអូនៅតាមសហគមន៍ផងដែរ។ បឹងទាំងពីរ នឹងរៀបចំរបាយការណ៍មួយអំពីការរៀនសូត្ររួមគ្នា និងសៀវភៅមួយអំពីអភិបាលកិច្ចបឹង។

## គម្រោងនេះ នឹងនាំមកនូវលទ្ធផលដូចខាងក្រោម៖

→ អភិបាលកិច្ចបឹង ដោយផ្អែកលើគោលការណ៍ IWRM ត្រូវបានពង្រឹង។

→ ការយល់ដឹងអំពីជម្រើសគោលនយោបាយដើម្បីទ្រទ្រង់របរចិញ្ចឹមជីវិត ដែលផ្អែកលើនិរន្តរភាពនៃធនធាន ត្រូវបានកែលំអ។

→ ការយល់ដឹងជាសាធារណៈអំពីការអភិវឌ្ឍន៍ និងការថែរក្សាបឹងឲ្យបានល្អ ត្រូវបានបង្កើន។

សកម្មភាពរួម ដំណោះស្រាយរួម





**លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ**
ផ្ទះលេខ ១៨៤ ផ្លូវ ហ្វាងួម
ប្រអប់សំបុត្រលេខ ៦១០១ ទីក្រុង វៀងច័ន្ទ ប្រទេសឡាវ
ទូរស័ព្ទ: +៨៥៦ ២១ ២៦៣ ២៦៣
ទូរសារ: +៨៥៦ ២១ ២៦៣ ៣៦៤
អ៊ីម៉ែល: mrcs@mrcmekong.org
www.mrcmekong.org



© រក្សាសិទ្ធិគ្រប់យ៉ាង ដោយគណៈកម្មការទន្លេមេគង្គ ឆ្នាំ ២០១៧